អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖

- ការមកដល់ទេសចរអន្តរជាតិ ចូលកម្ពុជាតាមរយៈព្រលានយន្តហោះទាំងបីកន្លែងមានការធ្លាក់ចុះ ៩២%
- ការនាំចេញកសិផលរបស់កម្ពុជាកើនឡើង ៨៩,៧% ក្នុងរយៈពេល៨ ខែដំបូង
- កម្ពុជាផ្តើមពង្រឹងការយកពន្ធនាំចូលទូរស័ព្ទចល័ត និងឧបករណ៍ប្រើប្រាស់ស៊ីមកាត
- រដ្ឋមន្ត្រី ថោង ខុន៖ សប្តាហ៍ទី១ នៃខែកញ្ញា មានភ្ញៀវទេសចរចេញដើរកម្សាន្តជាង ៥ម៉ឺននាក់
- ADB៖ កម្ពុជាកំពុងបោះជំហានល្អ លើផ្លូវវែងឆ្ងាយ ឆ្ពោះទៅរកកំណើនសេដ្ឋកិច្ចកាបូនទាប
- ក្រសួងយុត្តិធម៌ និង ADB ពិភាក្សាគ្នា បង្កើតតុលាការពាណិជ្ជកម្មនៅកម្ពុជា
- ការនាំចេញកង់របស់កម្ពុជា ទទួលបានទំហំទឹកប្រាក់ជាង ៤១៦លានដុល្លារ
- យុទ្ធសាស្ត្រពាណិជ្ជកម្មរបស់វៀតណាមស្វែងរកដៃគូសក្តានុពល បង្កើនការនាំចេញទៅអង់គ្លេស
- សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់(CPI) របស់ថៃធ្លាក់ចុះជាលើកដំបូងក្នុងរយៈពេល៥ខែ
- ការនាំចេញផលិតផលកសិកម្មពីកម្ពុជាទៅប្រទេសវៀតណាម មានការកើនឡើង
- អាកាសចរណ៍វៀតណាម បង្ហាញផែនការបើកជើងហោះហើរទៅកាន់ សហរដ្ឋអាមេរិក ជាលើកដំបូងបំផុត
- តុល្យភាពគណនេយ្យចរន្តរបស់ប្រទេសសមាជិកអាស៊ានចាប់ពីឆ្នាំ២០១៩-២០២២ (% ផ.ស.ស)
- គម្រោងអត្ថប្រយោជន៍សម្រាប់អ្នកគ្មានការងារធ្វើរបស់សហរដ្ឋអាមេរិក បានដល់កាលកំណត់
- សហព័ន្ធអារ៉ាប់រួម ប្រកាសពីគម្រោង និងការផ្តួចផ្តើមថ្មី ចំនួន៥០ ដើម្បីជំរុញសេដ្ឋកិច្ច
- ផែនការកំណត់ពន្ធលើការបញ្ចេញកាបូនរបស់សហភាពអឺរ៉ុប នឹងប៉ះពាល់ដល់សេដ្ឋកិច្ចប្រទេសជាច្រើន
- សេដ្ឋកិច្ចឥណ្ឌាបានស្ទុះឡើង២០%ក្នុងត្រីមាសទី២ឆ្នាំនេះ ក្រោយអត្រាចាក់វ៉ាក់សាំងកើនឡើងជាលំដាប់


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២១ លេខ ៖ ៨៤

# ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

## ការមកដល់នៃភ្ញៀវទេសចរអន្តរជាតិ ចូលមកប្រទេសកម្ពុជាតាមរយៈព្រលានយន្តហោះទាំងបីកន្លែងមានការធ្លាក់ចុះ ៩២%



*ប្រភព៖postkhmer ២០២១, រូបភាព៖ ហេង ជីវ័ន*

យោងតាមទិន្នន័យពីក្រសួងទេសចរណ៍បានបង្ហាញថា៖ គិតត្រឹមរយៈពេលពីខែមករាទៅដល់ខែកក្កដានៃឆ្នាំ ២០២១ ចំនួនភ្ញៀវទេសចរបរទេសធ្វើដំណើរមកកម្ពុជាតាមរយៈអាកាសយានដ្ឋានអន្តរជាតិទាំងបី មានប្រមាណ ៥ ម៉ឺននាក់ ធ្លាក់ចុះដាង ៩២%ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០ ដែលមានចំនួន៦៩ម៉ឺននាក់។ ក្នុងនោះភ្ញៀវទេសចរអន្តរជាតិដែលមកប្រទេសកម្ពុជាតាមរយៈអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មានចំនួន ៤៣ ៩០៩ នាក់ ធ្លាក់ចុះ ៨៨,៧%, អាកាសយានដ្ឋានអន្តរជាតិកងកេង ខេត្តព្រះសីហនុ មានចំនួន ៧ ៨១៦ នាក់ ធ្លាក់ចុះ ៨៧,៥% និងអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាបមានចំនួន ៤ នាក់ ធ្លាក់ចុះ ១០០%។

ដោយឡែកសម្រាប់ចំនួនទេសចរបរទេសធ្វើដំណើរមកប្រទេសកម្ពុជាតាមមធ្យោបាយ (ផ្លូវគោក អាកាស និងផ្លូវទឹក) ក្នុងរយៈពេល ៧ ខែឆ្នាំ ២០២១ មាន ១១២ ៥៤៤ នាក់ ធ្លាក់ចុះ ៩០,៦%ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន។ តាមរយៈប្រធានសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា បានឱ្យដឹងថាប្រទេស កម្ពុជាគួរចាប់យកឱកាសឱ្យបានក្នុងពេលឆាប់ៗនេះ ដើម្បីប្រកាសដំណឹងពីការបើកទទួលភ្ញៀវទេសចរចាក់វ៉ាក់សាំងប្រឆាំងនឹងកូវីដ-១៩ គ្រប់ដូសរួចរាល់ ព្រោះកម្ពុជាត្រូវបានគេទទួលស្គាល់ថាអាចគ្រប់គ្រងការឆ្លងរាលដាលជំងឺកូវីដ-១៩ បានល្អ និងមានអត្រាប្រជាជនចាក់វ៉ាក់សាំងបានច្រើនជាប់លេខ ២ ក្នុងតំបន់ បន្ទាប់ពីប្រទេសសិង្ហបុរី។

កាលពីដើមខែមេសា ឆ្នាំ២០២១ កន្លងទៅនេះ ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានស្នើសុំឱ្យសម្តេចអគ្គមហាសេនាបតីតេជោ ដែលជានាយករដ្ឋមន្ត្រី ពិចារណាពីការបើកទ្វារទទួលភ្ញៀវទេសចរអន្តរជាតិ ដែលបានចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ គ្រប់ដូសរួចហើយ ចាប់ពីត្រីមាសទី ៤ ឆ្នាំ ២០២១ នេះតទៅ។

បច្ចុប្បន្ននេះក្រសួងទេសចរណ៍ និងវិស័យឯកជន កំពុងសហការគ្នាយ៉ាងសកម្មក្នុងការរៀបចំផែនការ ក៏ដូចជាដាក់ចេញវិធានការថ្មីៗជាច្រើន ដើម្បីត្រៀមបើកទទួលភ្ញៀវទេសចរអន្តរជាតិចាក់វ៉ាក់សាំងគ្រប់ចំនួន ក្នុងពេលឆាប់ៗនេះ ដែលអាចនឹងចាប់ផ្តើមនៅអំឡុងខែវិច្ឆិកា ឬខែធ្នូខាងមុខ។ *ដោយ សេន ចន្ទ*

*ប្រភព៖ postkhmer, ចេញផ្សាយថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១*

## ការនាំចេញកសិផលរបស់កម្ពុជាកើនឡើង ៨៩,៧% ក្នុងរយៈពេល៨ខែដំបូង ដោយទទួលបានប្រាក់ចំណូលប្រមាណ ៣,២៣ ពាន់លានដុល្លារអាមេរិក



*ប្រភព ៖ khmertimes*

ប្រទេសកម្ពុជាបាននាំចេញកសិផលចំនួន៥,៥៤ លានតោនក្នុងរយៈពេល ៨ ខែដំបូងនៃឆ្នាំ ២០២១ កើនឡើងជាងឆ្នាំមុន ៨៩,៧% ដែលបាននាំចេញត្រឹមតែ ២,៩២ លានតោន ក្នុងរយៈពេលដូចគ្នា។

ប្រទេសកម្ពុជាបាននាំចេញកសិផលទៅកាន់ ៦៦ប្រទេស ហើយកសិផលសំខាន់ៗសម្រាប់នាំចេញ រួមមានអង្ករ កៅស៊ូ ដំឡូងមី ស្វាយ ចេកស្រស់ ម្រេច គ្រាប់ស្វាយចន្ទី ពោត ប្រេងដូង ថ្នាំជក់ និងផលិតផលផ្សេងៗទៀត។

ក្នុងរយៈពេល៨ខែ ឆ្នាំ២០២១ ការនាំចេញកសិផលផ្សេងៗទៀតក្រៅពីអង្ករមានការកើនឡើងដល់១១០% ខណៈដែលការនាំចេញអង្ករមានការថយចុះចំនួន ២៣,៣៧% ដោយសារកង្វះទូកុងតេន័រសម្រាប់ផ្ទុក និងតម្លៃដឹកជញ្ជូនមានការកើនឡើង។ ប្រទេសចិននៅតែជាអ្នកទិញអង្ករដ៏ធំរបស់កម្ពុជា ដែលស្មើនឹង៤៨% នៃការនាំចេញអង្ករសរុបរបស់កម្ពុជា។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖khmertimes ចេញផ្សាយថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២១។*

## កម្ពុជាផ្ដើមពង្រឹងការយកពន្ធនាំចូលទូរស័ព្ទចល័ត និងឧបករណ៍ប្រើប្រាស់ស៊ីមកាត



*រូបថត ៖ ភ្នំពេញប៉ុស្តិ៍*

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា(អ.គ.រ) នឹងដាក់ដំណើរការនូវមុខងារគ្រប់គ្រងទូរស័ព្ទចល័ត និងឧបករណ៍ប្រើប្រាស់ស៊ីមកាតផ្សេងទៀត ដែលបានចាប់ផ្ដើមអនុវត្តពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១តទៅ ដើម្បីពង្រឹងការប្រមូលពន្ធ ស្របពេលការប្រើប្រាស់កំពុងមានការកើនឡើងជាគំហុក។

អ.គ.រ បានរៀបចំរួចរាល់នូវមុខងារគ្រប់គ្រងបរិក្ខាទាំងនេះនូវប្រព័ន្ធអេឡិចត្រូនិកគយ ដែលមានមុខងារកត់ត្រា និងគ្រប់គ្រងលេខអត្តសញ្ញាណឧបករណ៍អន្តរជាតិ (IMEI) នៃទូរស័ព្ទចល័ត និងឧបករណ៍ប្រើប្រាស់ស៊ីមកាតផ្សេងទៀតឱ្យបំពេញកាតព្វកិច្ចពន្ធ និងអាករតាមបទប្បញ្ញត្តិជាធរមាន។ នីតិវិធីលម្អិតនៃការអនុវត្តមុខងារនេះមាននៅក្នុង «សៀវភៅមគ្គុទ្ទេសក៍មុខងារគ្រប់គ្រងទូរស័ព្ទចល័ត និងឧបករណ៍ប្រើប្រាស់ស៊ីមកាតផ្សេងៗទៀត» ដែលអាចរកបានលើគេហទំព័រផ្លូវការអ.គ.រ។

ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិត បានកើនឡើងដល់ ១៥,៥លាននាក់ ដែលរួមទាំងអ្នកប្រើប្រាស់អ៊ីនធឺណិតចល័តផងដែរ។ ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិតខ្សែ និងលើតុមានចំនួន ៥២ ៤៨០ ប៉ុណ្ណោះ គិតត្រឹមចុងខែឧសភា ឆ្នាំ២០២១។ ចំនួនអ្នកប្រើអ៊ីនធឺណិតចល័ត

មានការធ្លាក់ចុះ ប៉ុន្តែអ្នកប្រើអ៊ីនធឺណិតលើគុ មានកំណើន។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ភ្នំពេញបុស្តិ៍ ចេញផ្សាយថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០២១។*

## រដ្ឋមន្រ្តី ថោង ខុន៖ សប្តាហ៍ទី១ នៃខែកញ្ញា មានភ្ញៀវទេសចរចេញដើរកម្សាន្តជាង ៥ម៉ឺននាក់



*ប្រភព ៖ freshnewsasia*

សកម្មភាពទេសចរណ៍ក្នុងប្រទេស ចាប់ផ្តើមមានជាបណ្តើរៗឡើងវិញ បន្ទាប់ពីរាជរដ្ឋាភិបាលបានបិទបញ្ចប់យុទ្ធនាការពង្រឹងវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ១៩ កាលពីទី១៩ ខែសីហា ឆ្នាំ២០២១នេះ។ ក្នុងសប្តាហ៍ទី១ នៃខែកញ្ញា ឆ្នាំ ២០២១ (ថ្ងៃទី៤-៥) នៅទូទាំងប្រទេសកម្ពុជាទទួលបានភ្ញៀវទេសចរប្រមាណជាង ៥១ ០៤២ នាក់ ក្នុងនោះមានភ្ញៀវជាតិ ៥០ ១៣៤ នាក់ និងភ្ញៀវបរទេសផ្ទៃក្នុង ៩០៨នាក់។ គោលដៅទេសចរណ៍សំខាន់ៗ រួមមាន ខេត្តកំពត ខេត្តកែប រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តតាកែវ។

រដ្ឋបាលខេត្តភាគច្រើន បានអនុញ្ញាតសកម្មភាពទេសចរណ៍នៅតាមរមណីយដ្ឋាន និងគោលដៅទេសចរណ៍នានា ក្រោមការគ្រប់គ្រងប្រកបដោយភាពហ្មត់ចត់ និងប្រយ័ត្នប្រយែង ពិសេសការពង្រឹងការអនុវត្តវិធានការ «៣-កុំ និង ៣-ការពារ»។

កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ក្រសួងទេសចរណ៍បានដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីស្តង់ដាប្រតិបត្តិអប្បបរមា (ហៅកាត់ថា SOP) តាមគន្លងប្រក្រតីភាពថ្មី សម្រាប់អាជីវកម្មទេសចរណ៍ធំៗចំនួន៤គឺ អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ អាជីវកម្មភោជនីយដ្ឋាន-អាហារដ្ឋានទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ និងសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ដើម្បីធានាបាននូវសុវត្ថិភាពជូនដល់ភ្ញៀវទេសចរជាតិ-អន្តរជាតិ ដែលស្របតាមវិធានការចាំបាច់របស់រាជរដ្ឋាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ ក្រសួងទេសចរណ៍នឹងធ្វើការពិភាក្សាជាមួយរដ្ឋបាលខេត្តផ្សេងៗទៀត ដើម្បីជំរុញទេសចរណ៍ក្នុងស្រុក ដោយពិនិត្យពិចារណាលើការបើកដំណើរការសកម្មភាពរមណីយដ្ឋាន និងគោលដៅទេសចរណ៍ឡើងវិញពិសេសដើម្បីត្រៀមក្នុងរដូវភ្ជុំបិណ្ឌដែលជិតមកដល់ និងចូលរួមត្រៀមរៀបចំការបើកទទួលទេសចរអន្តរជាតិឡើងវិញនៅពេលខាងមុខផងដែរ។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnewsasia ចេញផ្សាយថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០២១*

## ADB៖ កម្ពុជាកំពុងបោះជំហានល្អ លើផ្លូវវែងឆ្ងាយ ឆ្ពោះទៅរកកំណើនសេដ្ឋកិច្ចកាបូនទាប



*By Pen Srey Neat*

នៅក្នុងសំណេរនាយិកានៃនិវេសដ្ឋានបេសកកម្មប្រចាំកម្ពុជារបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ដែលមានចំណងជើងថា *កម្ពុជាកំពុងបោះជំហានល្អលើផ្លូវវែងឆ្ងាយឆ្ពោះទៅរកកំណើនសេដ្ឋកិច្ចកាបូនទាប* បានបង្ហាញថា ទោះបីជាប្រទេសកម្ពុជារួមចំណែកតិចតួចត្រឹមតែ ០,០២% ក្នុងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពិភពលោកក៏ដោយ ក៏កម្ពុជានៅតែមានភាពងាយរងគ្រោះខ្លាំងពីការប្រែប្រួលអាកាសធាតុ ដូចជាការកើនឡើង នៃទឹកជំនន់ និងគ្រោះរាំងស្ងួតធ្ងន់ធ្ងរ ដែលមានផលប៉ះពាល់ដល់ការផលិតស្បៀងអាហារ ជាពិសេសដំណាំស្រូវ។ នៅក្នុងសំណេរបានបង្ហាញបន្តទៀតថា នៅឆ្នាំ ២០៣០ ការបាត់បង់ព្រៃឈើ និងការប្រើប្រាស់ដីក្នុងគោលបំណងផ្សេងទៀត នឹងបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រចាំឆ្នាំរបស់ប្រទេសកម្ពុជា រហូតដល់៤៩% ហើយបន្ទាប់មកវិស័យថាមពល២២% និងវិស័យកសិកម្ម១៧,៥%។

មានគោលនយោបាយ និងសកម្មភាពសំខាន់ៗដែលរាជរដ្ឋាភិបាល និងវិស័យផ្សេងទៀតនៅប្រទេសកម្ពុជាគួរពិចារណាដើម្បីជួយប្រទេសឆ្ពោះទៅរកកំណើនសេដ្ឋកិច្ចកាបូនទាប ដូចជា ការបន្ថយការកាប់ព្រៃឈើ ការដាំដើមឈើឡើងវិញ ការលើកកម្ពស់ការគ្រប់គ្រងធនធានជាប្រព័ន្ធ ព្រមទាំងឥន្ទនៈស្អាត អាចជួយកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ជួយកាត់បន្ថយការខូចខាតបង្កដោយទឹកជំនន់នៅទីក្រុង និង ជនបទ និងកាត់បន្ថយការចំណាយលើការស្តារហេដ្ឋារចនាសម្ព័ន្ធដែលមានតម្លៃខ្ពស់។

កំណើនកាបូនលែងជាទំនួលខុសត្រូវតែឯងរបស់រាជរដ្ឋាភិបាលទៀតហើយ គឺត្រូវដោះស្រាយទាំងក្នុងប្រទេស ក្នុងតំបន់ និងទូទាំងពិភពលោក។ អ្នកបង្កើតត្រូវគិតគូរក្នុងការផ្តល់ហិរញ្ញប្បទាន ដើម្បីជាការលើកទឹកចិត្តក្នុងការកាត់បន្ថយការបំភាយឧស្ម័នពុល។ ហើយប្រព័ន្ធជួញដូរការបញ្ចេញឧស្ម័ន ឬទីផ្សារកាបូនគឺជាមធ្យោបាយមួយដើម្បីកំណត់ការចំណាយខាងលើ។ បណ្តាប្រទេសនៃក្រុមអនុតំបន់មេគង្គ ដែលរួមមានកម្ពុជា និងផ្នែកខ្លះនៃសាធារណរដ្ឋប្រជាមានិតចិន ក៏បានគិតគូរពីការអភិវឌ្ឍទីផ្សារថាមពលក្នុងតំបន់ ដោយសារផលិតកម្មធ្យូងថ្មដែលជាប្រភពឥន្ទនៈបំពុលច្រើនបំផុតនៅក្នុងតំបន់។

ចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ២០២០ កម្ពុជាបានលក់ឥណទានកាបូនដែលមានតម្លៃ ១១,៦ លានដុល្លារ ពីទីតាំងចំនួនបីគឺ ដែនជម្រកសត្វព្រៃកែវសីមា ឧទ្យានជាតិក្រវាញខាងត្បូង និងដែនជម្រកសត្វព្រៃតាតៃ។ ឧបករណ៍គោលនយោបាយមួយទៀតដែលកម្ពុជាគួរពិចារណាដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័ន គឺការកំណត់ពន្ធកាបូន ឬតម្លៃក្នុងមួយតោននៃការបញ្ចេញកាបូន ដើម្បីឱ្យក្រុមហ៊ុនឃើញពីផលប៉ះពាល់បរិយាកាស និងសង្គម និងចូលរួមកាត់បន្ថយកាបូនក្នុងសកម្មភាពរបស់ខ្លួន។

កាលពីអតីតកាល ដើម្បីគាំទ្រដល់ការវិនិយោគបៃតង រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តអត្រាពន្ធនាំចូលអនុគ្រោះសម្រាប់ការវិនិយោគបរិស្ថានមេត្រី(feed-in-tariffs) សម្រាប់បច្ចេកវិទ្យាថាមពលកកើតឡើងវិញប៉ុន្តែឧបករណ៍គោលនយោបាយនេះ លែងមានតម្រូវការទៀតហើយ ដោយសារការចំណាយលើការប្រើបច្ចេកវិទ្យាថាមពលកកើតឡើងវិញដូចជា ថាមពលព្រះអាទិត្យ និងថាមពលខ្យល់មានការធ្លាក់ចុះគួរឱ្យកត់សម្គាល់។ ដូច្នេះ ដើម្បីកាត់បន្ថយការចំណាយ លើថាមពលកកើតឡើងវិញបន្ថែមទៀត ប្រទេសកម្ពុជាប្រើប្រាស់ការ

ដេញថ្លៃ ឧទាហរណ៍ ដូចជាការដេញថ្លៃប្រកបដោយការប្រកួតប្រជែង។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ CEN ចេញផ្សាយថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១។*

## ក្រសួងយុត្តិធម៌ និង ADB ពិភាក្សាគ្នា បង្កើតតុលាការពាណិជ្ជកម្មនៅកម្ពុជា




*ប្រភព ៖ SWIFT NEWS*

ក្រសួងយុត្តិធម៌ បានជួបជាមួយធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ដើម្បីពិភាក្សាអំពីកិច្ចសហការក្នុងការបង្កើតតុលាការពាណិជ្ជកម្មនៅកម្ពុជា។ កិច្ចពិភាក្សាដោយផ្តោតលើចំណុចសំខាន់ៗចំនួន៤គឺ ១-ដំណើរការនៃការរៀបចំក្របខ័ណ្ឌច្បាប់ និងបទដ្ឋានគតិយុត្តសម្រាប់ដំណើរការតុលាការពាណិជ្ជកម្ម ២-ការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់បម្រើការងារនៅក្នុងតុលាការពាណិជ្ជកម្ម ៣-ការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសម្ភារៈរបស់តុលាការពាណិជ្ជកម្ម ៤-ការធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាក្នុងការគ្រប់គ្រងនិងដំណើរការរបស់តុលាការពាណិជ្ជកម្ម។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖SWIFTNEWS ចេញផ្សាយថ្ងៃទី០៨ខែកញ្ញាឆ្នាំ២០២១។*

## ការនាំចេញកង់របស់កម្ពុជា ទទួលបានទំហំទឹកប្រាក់ជាង ៤១៦លានដុល្លារ




*ប្រភព ៖ pnn*

នៅក្នុងរយៈពេល ៨ខែ ដើមឆ្នាំ២០២១នេះ កម្ពុជាសម្រេចនាំចេញកង់ទៅទីផ្សារអន្តរជាតិ ក្នុងទំហំទឹកប្រាក់សរុបជាង ៤១៦លានដុល្លារ បានកើនឡើងជាង ៨២លានដុល្លារ បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ កំណើននៃការនាំចេញកង់នាពេលនេះគឺដោយសារកិច្ចខិតខំរបស់ក្រសួងពាណិជ្ជកម្ម និងក្រសួងពាក់ព័ន្ធ ក្នុងការអំពាវនាវដល់អ្នកបញ្ជាទិញឱ្យបន្តការបញ្ជាទិញ ខណៈដែលពួកគេមានការទុកចិត្តចំពោះការផលិត និងផ្គត់ផ្គង់របស់កម្ពុជា និងមួយវិញទៀតគឺដោយសារកម្ពុជាមានទីផ្សារទូលំទូលាយ និងការគ្រប់គ្រងបានល្អប្រសើរក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ កំណើននេះបាននឹងកំពុងជំរុញឱ្យសេដ្ឋកិច្ចកម្ពុជា មានកំណើនបន្ថែមទៀត។

តាមស្ថិតិកាលខែមីនា ២០២១ រោងចក្រផលិតកង់ធំៗនៅខេត្តស្វាយរៀង មានចំនួន៥រោងចក្រ និងនាំចេញបានប្រមាណ ១លាន៨៦ ម៉ឺនគ្រឿង ទៅកាន់ទីផ្សារជាង ៥០ ប្រទេស។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ pnnចេញផ្សាយថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១។*

# តារាងប្រចាំសប្តាហ៍

## តារាងទី១ ការចំណាយលើអត្ថប្រយោជន៍សង្គមប្រចាំខែមិថុនា ឆ្នាំ២០២១

តាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថាៈ នៅក្នុងខែមិថុនា ឆ្នាំ២០២១ រដ្ឋបាលថ្នាក់ជាតិបានចំណាយលើអត្ថប្រយោជន៍សង្គម ក្នុងទំហំទឹកប្រាក់សរុបចំនួន ៣៦៥,៥៣ប៊ីលានរៀល ដែលមានការធ្លាក់ចុះបន្តិចប្រមាណជា ៣%បើធៀបនឹងខែឧសភានៃឆ្នាំ២០២១។ ជាក់ស្តែង ការចំណាយលើជំនួយសង្គមដល់ប្រជាពលរដ្ឋ មានទឹកប្រាក់ចំនួន ២៥៥,៩២ ប៊ីលានរៀល នៅក្នុងខែមិថុនា ឆ្នាំ២០២១ ដែលមានការធ្លាក់ចុះប្រមាណជា ៤,១% បើធៀបនឹងខែឧសភា។

ម្យ៉ាងវិញទៀត ការចំណាយលើអំណោយពីពហុភាគីសំរាប់ចំណាយវិនិយោគ មានទំហំទឹកប្រាក់៩,៦២ប៊ីលានរៀល នៅក្នុងខែមិថុនា ឆ្នាំ២០២១ ដែលបានធ្លាក់ចុះប្រមាណជា១៨% បើធៀបនឹងខែឧសភា។

ដោយឡែក ការចំណាយអត្ថប្រយោជន៍សង្គមផ្សេងៗទៀត មិនមានទេនៅក្នុងខែមិថុនា ឆ្នាំ២០២១នេះ ។

ក៏ប៉ុន្តែ ការចំណាយលើអត្ថប្រយោជន៍សន្តិសុខសង្គម មានទឹកប្រាក់ចំនួន ៩៩,៩៩ប៊ីលានរៀល នៅខែមិថុនា ឆ្នាំ២០២១ ដែលមានការកើនឡើងប្រមាណជា៧,៧% បើធៀបនឹងខែឧសភា ឆ្នាំ២០២១៕ដោយ មិត្ត ចន្ទី

| ការចំណាយឆ្នាំ២០២១(គិតជាប៊ីលានរៀល) | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
|---|---|---|---|---|---|---|
| **អត្ថប្រយោជន៍សង្គម** | **103.40** | **114.72** | **240.59** | **115.28** | **376.94** | **365.53** |
| កំណើន/ថយ(%) | | 10.9% | 109.7% | -52.1% | 227.0% | -3.0% |
| អត្ថប្រយោជន៍សន្តិសុខសង្គម | 90.63 | 101.04 | 158.63 | 39.06 | 92.81 | 99.99 |
| កំណើន/ថយ(%) | | 11.5% | 57.0% | -75.4% | 137.6% | 7.7% |
| ជំនួយសង្គមដល់ប្រជាពលរដ្ឋ | 9.54 | 8.85 | 75.32 | 65.65 | 266.78 | 255.92 |
| កំណើន/ថយ(%) | | -7.2% | 751.1% | -12.8% | 306.4% | -4.1% |
| អំណោយពីពហុភាគីសំរាប់ចំណាយវិនិយោគ | 3.23 | 4.83 | 6.64 | 10.57 | 11.73 | 9.62 |
| កំណើន/ថយ(%) | | 49.5% | 37.5% | 59.2% | 11.0% | -18.0% |
| អត្ថប្រយោជន៍សង្គមផ្សេងៗទៀត | - | - | - | - | 5.62 | - |

ប្រភពៈតារាងប្រតិបត្តិការហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ខែមិថុនាឆ្នាំ២០២១

## តារាងទី២ ពាណិជ្ជកម្មរវាងកម្ពុជា និងប្រទេសថៃលើមុខទំនិញ នៅក្នុងខែកក្កដា ឆ្នាំ២០២១

យោងទៅតាមទិន្នន័យរបស់ធនាគារជាតិប្រទេសថៃ បានបង្ហាញថាៈ នៅក្នុងខែកក្កដា ឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងប្រទេសថៃ មានទំហំទឹកប្រាក់ប្រមាណជា ៦៣០,៤៧លានដុល្លារ ដែលមានកំណើនបន្តិចប្រមាណជា ២,៣% បើធៀបនឹងខែមិថុនានៃឆ្នាំដដែល។

ជាក់ស្តែង ការនាំចូលទំនិញរបស់ប្រទេសថៃ មកកម្ពុជា មានទំហំទឹកប្រាក់ ៥៧៧,៥០លានដុល្លារ នៅក្នុងខែកក្កដា ឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា ៣,១% បើធៀបនឹងខែមិថុនា។

ក៏ប៉ុន្តែ ការនាំចេញទំនិញរបស់កម្ពុជាទៅប្រទេសថៃ មានទំហំទឹកប្រាក់ប្រមាណជា ៥២,៩៧លានដុល្លារ នៅក្នុងខែ កក្កដា ឆ្នាំ២០២១ ដែលមានការធ្លាក់ចុះប្រមាណជា៥,៣%បើធៀបនឹងខែមិថុនាឆ្នាំ២០២១៕

ដោយ មិត្ត ចន្ទី

*ឯកតាៈ គិតជាលានដុល្លារអាមេរិក*

| បរិយាយ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា |
|---|---|---|---|---|---|---|---|
| **ទំហំពាណិជ្ជកម្ម** | **653.39** | **644.76** | **799.19** | **596.61** | **671.83** | **616.20** | **630.47** |
| កំណើន% | | -1.3% | 24.0% | -25.3% | 12.6% | -8.3% | 2.3% |
| កម្ពុជានាំចេញទៅថៃ | 113.22 | 112.05 | 104.27 | 72.63 | 57.65 | 55.93 | 52.97 |
| កំណើន% | | -1.0% | -6.9% | -30.3% | -20.6% | -3.0% | -5.3% |
| ថៃនាំចូលមកកម្ពុជា | 540.17 | 532.71 | 694.92 | 523.98 | 614.18 | 560.27 | 577.50 |
| កំណើន% | | -1.4% | 30.4% | -24.6% | 17.2% | -8.8% | 3.1% |

*ប្រភពៈធនាគារជាតិប្រទេសថៃ*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### យុទ្ធសាស្ត្រពាណិជ្ជកម្មរបស់វៀតណាម ក្នុងការស្វែងរកដៃគូសក្តានុពលដើម្បីបង្កើនការនាំចេញទៅកាន់ចក្រភពអង់គ្លេស



*ប្រភព៖ Viet Nam News , រូបភាព៖ Thanh Vân*

ក្រុមហ៊ុននាំចេញផលិតផលកសិកម្មវៀតណាមចង់បង្កើតទំនាក់ទំនងអាជីវកម្មរយៈពេលវែងជាមួយចក្រភពអង់គ្លេស ដែលជាប្រទេសមានសេដ្ឋកិច្ចធំទី២នៅអឺរ៉ុប។ ការណ៍នេះតម្រូវឱ្យមានយុទ្ធសាស្ត្រមួយសមស្រប ក្នុងការទាក់ទាញដៃគូសក្តានុពល ដើម្បីទាញយកប្រយោជន៍ និងឱកាសនៃការនាំចេញកាន់តែច្រើនបន្ថែមទៀត ។

លោក Nguyễn Cảnh Cường ទីប្រឹក្សាពាណិជ្ជកម្មវៀតណាមនៅចក្រភពអង់គ្លេស បានលើកឡើងនៅក្នុងសិក្ខាសាលាដែលរៀបចំឡើងដោយការិយាល័យពាណិជ្ជកម្មវៀតណាម ប្រចាំនៅចក្រភពអង់គ្លេស និងទីភ្នាក់ងារជំរុញពាណិជ្ជកម្ម ក្រោមក្រសួងឧស្សាហកម្មនិងពាណិជ្ជកម្មវៀតណាម ដោយមានការចូលរួមពីតំណាងទីភ្នាក់ងារ អង្គការសហគ្រាសនាំចេញកសិផលវៀតណាមថា៖ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីវៀតណាម-ចក្រភពអង់គ្លេស (UKVFTA) បានចូលជាធរមានកាលពីខែឧសភាកន្លងទៅ ដែលស្របទៅនឹងតម្រូវការអាជីវកម្មរបស់ប្រទេសអង់គ្លេស ក្នុងការស្វែងរកអ្នកផ្គត់ផ្គង់នៅខាងក្រៅសហភាពអឺរ៉ុប បន្ទាប់ពីការចាកចេញរបស់ខ្លួនពីសហភាពអឺរ៉ុប (Brexit)។ កត្តាខាងលើទាំងនេះ បានបង្កើតប្រយោជន៍ដល់ផលិតផលកសិកម្មវៀតណាម ក្នុងការប្រកួតប្រជែងនៅទីផ្សារចក្រភពអង់គ្លេស ជាបន្តបន្ទាប់ និងឱកាសកាន់តែច្រើនឡើងសម្រាប់កិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរ។

ទន្ទឹមនឹងនេះ ផលិតផលកសិកម្មមួយចំនួនផ្សេងទៀត ដូចជាអង្ករ និងផ្លែឈើមានលក់តែនៅក្នុងផ្សារទំនើបតូចប៉ុណ្ណោះហើយមិនមានលទ្ធភាពចូលទៅកាន់ផ្សារទំនើបធំៗ នៅក្នុងប្រទេសអង់គ្លេសនៅឡើយទេ ដែលនេះបានបង្ហាញពីសក្តានុពលដ៏ធំសម្រាប់ផលិតផល កសិផល និងបន្លែរបស់វៀតណាមដើម្បីចូលទីផ្សារអង់គ្លេស។

ដើម្បីចូលទីផ្សារអង់គ្លេសបាន លុះត្រាតែគ្រប់ផលិតផលត្រូវរក្សាបាននូវស្តង់ដារ GlobalGAP ព្រោះនេះគឺជាការយកឈ្នះសេចក្តីទុកចិត្តពីអតិថិជនក្នុងការប្រើប្រាស់។ បន្ថែមពីនេះស្តង់ដារ GlobalGAP នឹងជួយឱ្យអាជីវកម្មវៀតណាមអភិវឌ្ឍប្រកបដោយនិរន្តរភាព និងឈរនៅលើទីផ្សារបរទេស៕

*ដោយ មុំ ចិន្តា*

*ប្រភព៖Vite Name News ចេញផ្សាយថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២១*

## សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់(CPI) របស់ថៃធ្លាក់ចុះជាលើកដំបូងក្នុងរយៈពេល៩ខែ



*ប្រភព៖ Bangkok Post , រូបភាព៖ Varuth Hirunvtheb*

វិធានការរបស់រដ្ឋាភិបាល ដើម្បីកាត់បន្ថយចំណាយសម្រាប់ជីវភាពរស់នៅរបស់ប្រជាជនតាមរយៈការបញ្ចុះថ្លៃផលិតផលកសិកម្មមួយចំនួន និងថ្លៃប្រេងឥន្ធនៈ បានជំរុញឱ្យអតិផរណា ដោយសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់(CPI) ធ្លាក់ចុះនៅក្នុងខែសីហាជាលើកដំបូងក្នុងរយៈពេល៩ខែ(មីនា-សីហា)។

យោងតាមរបាយការណ៍របស់ក្រសួងពាណិជ្ជកម្មបានបង្ហាញថា អតិផរណារបស់ថៃបានធ្លាក់ចុះ ០,០២% នៅក្នុងខែសីហា ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំកន្លងទៅ បន្ទាប់ពីបានកើនឡើង ០,៤៥%នៅក្នុងខែកក្កដា ១,២៥%ខែមិថុនា ២,៤៤% ខែឧសភា និងខែមេសាមានរហូតដល់ ៣,៤១% ឆ្នាំ២០២១ ហើយក៏ជាខែដែលមានអត្រាខ្ពស់បំផុតក្នុរយៈពេល៨ឆ្នាំចុងក្រោយនេះ។

ការធ្លាក់ចុះនេះ ភាគច្រើនត្រូវបានកំណត់ដោយវិធានការរបស់រដ្ឋាភិបាលជាពិសេសការកាត់បន្ថយថ្លៃសិក្សា និងថ្លៃប្រើប្រាស់មួយចំនួនផ្សេងទៀតដូចជា ៖ ថ្លៃសាច់ជ្រូក បន្លែ ផ្លែឈើស្រស់ និងប្រេងឥន្ធនៈមានថ្លៃទាបជាង បើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ខណៈពេលដែល ថ្លៃពងមាន់ និងគ្រឿងទេសនៅតែកើនឡើង។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ស្នូល Core CPI(ដោយមិនរាប់បញ្ចូលថ្លៃប្រែប្រួលម្ហូបអាហារ និងថាមពល) កើនឡើង ០,០៧% ក្នុងខែសីហាធៀបនឹងឆ្នាំកន្លងទៅ និងធ្លាក់ចុះពី០,១៤%កាលពីខែមុន។ ចំណែកឯសន្ទស្សន៍ថ្លៃប្រើប្រាស់(CPI)បានកើនឡើង ០,១៨%ពីខែកក្កដាឆ្នាំនេះ។

ក្នុងរយៈពេល ៨ ខែដំបូងឆ្នាំ២០២១ អតិផរណាជាមធ្យមគឺ ០,៧៣% និងអតិផរណាស្នូល ០,២៣% ធៀបនឹងឆ្នាំកន្លង។ គេរំពឹងថាអតិផរណាប្រចាំឆ្នាំនៅឆ្នាំ ២០២១ នឹងកើនឡើងក្នុងអត្រាចន្លោះពី ០,៧% ទៅ ១,៧% (ជាមធ្យម ១,២%) ដែលគេអាចចាត់ទុកថាសមស្របដើម្បីទ្រទ្រង់ សេដ្ឋកិច្ច។
សម្រាប់ខែកញ្ញា CPI ត្រូវបានគេព្យាករណ៍ថានឹងកើនឡើងក្នុងអត្រាបន្តិចម្តងៗ បន្ទាប់ពីការបញ្ចប់វិធានការរបស់រដ្ឋាភិបាលក្នុងការជួយកាត់បន្ថយថ្លៃដើមក្នុងការរស់នៅប្រចាំថ្ងៃដូចជាថ្លៃទឹក ភ្លើង ដូចខែសីហា កន្លងទៅនេះ៕ *ដោយ មុំ ចិន្តា*

*ប្រភព៖ Bangkok post ចេញផ្សាយថ្ងៃទី ៧ ខែកញ្ញាឆ្នាំ២០២១*

## ការនាំចេញផលិតផលកសិកម្ម ពីកម្ពុជាទៅប្រទេសវៀតណាមមានការកើនឡើង



*កសិករកំពុងប្រមូលផលស្រូវ ,រូបថតដោយ៖ Khmer Times*

ក្នុងអំលុងពេល ៨ខែចុងក្រោយនេះ កម្ពុជានាំចេញស្រូវប្រហែល ២,៤លានតោន កើនឡើងប្រមាណជា ៨៥,៩% បើធៀបទៅនឹងឆ្នាំមុន និងបាននាំចេញសណ្តែកខៀវទៅកាន់ប្រទេសវៀតណាមប្រមាណជា ២៣ ២៣០តោន កើនឡើង ៥ដងធៀបទៅនឹងឆ្នាំមុន។

គិតចាប់ពីខែមករា ដល់ខែសីហា កម្ពុជាបាននាំចេញដំឡូងមីស្រស់ទៅកាន់ប្រទេសវៀតណាម ចំនួន ៣៥៥ ៥៥០តោន ស្មើនឹង៧៥,៧% នៃការនាំចេញសរុប។ ការនាំចេញស្វាយចន្ទី ទៅកាន់ប្រទេសវៀតណាមមានចំនួន ៨៦៩ ៥៤០តោន ឬស្មើនឹង ៩៩,២% នៃការនាំចេញស្វាយចន្ទីសរុប និងការនាំចេញម្រេចមានចំនួន ២៤,៥លានតោន ស្មើនឹង ១០០% នៃការនាំចេញម្រេចសុរប។

វៀតណាមគឺជាដៃគូពាណិជ្ជកម្មនាំចេញធំបំផុតរបស់កម្ពុជា។ ផលិតផលកសិកម្មដែលវៀតណាមតែងតែនាំចូលពីកម្ពុជាមានដូចជាៈ សណ្តែកសៀង ដំឡូងមីស្រស់ ស្វាយចន្ទី ម្រេច ពោត និងផ្លែឈើផ្សេងៗមួយចំនួនទៀត។ សរុបមក គិតចាប់ពីខែមករា ដល់ខែសីហា កម្ពុជារកប្រាក់ចំណូលពីការនាំចេញផលិតផលកសិកម្មបានចំនួន ៣,២៣ប៊ីលានដុល្លារ និងបាននាំចេញផលិតផលសំខាន់ៗមួយចំនួនដូចជា អង្ករ ចេក កៅស៊ូ ដំឡូងមី ផ្លែស្វាយ ម្រេច ស្វាយចន្ទី និងពោត៕

*ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភពៈ គេហទំព័រ Khmer Times ចេញផ្សាយថ្ងៃទី7 ខែកញ្ញា ឆ្នាំ ២០២១*

## ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុកវៀតណាម បង្ហាញផែនការបើកជើងហោះហើរទៅកាន់ សហរដ្ឋអាមេរិក ជាលើកដំបូងបំផុត




*រូបភាពៈ ងួន សុភ័ត្រា*

ក្រុមហ៊ុនអាកាសចរណ៍ Vietnam Airlines បានបង្ហាញពីផែនការបើកជើងហោះហើរទៀងទាត់រវាង វៀតណាម និងសហរដ្ឋអាមេរិក ចាប់ពីខែតុលាឆ្នាំ ២០២១ខាងមុខនេះតទៅ ហើយវាជាជើងហោះហើរលើកដំបូងបំផុតក្នុងប្រវត្តិសាស្រ្ត បន្ទាប់ពីវៀតណាមចរចាអស់រយៈពេលជិត២០ឆ្នាំមកនេះ។ អំឡុងពេលដំបូង ក្រុមហ៊ុនអាចនឹងដឹកជញ្ជូនទំនិញ ព្រោះអ្នកដំណើរនៃប្រទេសទាំង២ អាចនឹងមានកម្រិតទាបនៅឡើយ។

តាំងពីឆ្នាំ២០២០មក ក្រុមហ៊ុននេះ បានប្រើប្រាស់ជើងហោះហើរមិនទៀងទាត់ ដើម្បីទទួលយកជនជាតិវៀតណាមនៅអាមេរិកដែលធ្វើមាតុនិវត្តន៍អំឡុងពេលកូវីដ១៩។ កាលពីឆ្នាំ ២០០៣ ក្រសួងដឹកជញ្ជូនវៀតណាម បានណែនាំឱ្យក្រុមហ៊ុនបម្រើសេវាកម្មហោះហើរដោយផ្ទាល់ជាមួយអាមេរិក ឱ្យបានត្រឹមឆ្នាំ ២០០៥ តែគម្រោងនេះ ត្រូវបានពន្យារពេលមកទល់ពេលនេះ ដោយសារតែក្តីបារម្ភពីប្រាក់ចំណេញ។ ទោះយ៉ាងណាក៏ដោយ មកទល់ពេលនេះ មានក្រុមហ៊ុន

អាកាសចរណ៍ដែលផ្តល់ជើងហោះហើរតម្លៃសមរម្យ ដូចជាក្រុមហ៊ុន Vietjet និងBamboo Airways ក៏បានបង្ហាញពីចំណាប់អារម្មណ៍ខ្ពស់ចំពោះជើងហោះហើរដោយផ្ទាល់ទៅកាន់អាមេរិកដែរ។

ក្រុមហ៊ុនអាកាសចរណ៍ Vietnam Airlines អាចនឹងប្រើប្រាស់យន្តហោះប្រភេទ Boeing 787 ឬក៏ប្រភេទ Airbus SE A350 នៅក្នុងកម្មវិធីសម្ពោធផ្លូវហោះហើរថ្មីរវាង ទីក្រុងហូជីមិញ និងទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ សហរដ្ឋអាមេរិក ដោយមានការចុះចតចាក់ប្រេងឥន្ទនៈតែម្តងប៉ុណ្ណោះ។

វិស័យអាកាសចរណ៍វៀតណាម នឹងអាចងើបឡើងវិញបាននៅក្នុង ឆ្នាំ ២០២៣-២០២៤ខាងមុខនេះ ដែលអាចនឹងត្រលប់មករកសភាពដើមវិញបាន ដូចកាលពីឆ្នាំ ២០១៩កន្លងទៅ។ បើតាមទិន្នន័យពីការិយាល័យស្ថិតិទូទៅវៀតណាម បានបង្ហាញថា នៅក្នុងរយៈពេល ៧ខែ ដើមឆ្នាំ ២០២១នេះ ក្រុមហ៊ុនអាកាសចរណ៍វៀតណាម បានបម្រើដល់អ្នកដំណើរជាង ១៣លាននាក់ ធ្លាក់ចុះ ៣២% ធៀបនឹងពេលដូចគ្នា កាលពីឆ្នាំ ២០២០៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ចេញផ្សាយថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១។*

## តុល្យភាពគណនេយ្យចរន្តរបស់ប្រទេសសមាជិក អាស៊ានចាប់ពីឆ្នាំ២០១៩-២០២២ (% ផ.ស.ស)

យោងតាមការព្យាករណ៍របស់ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូកបី (ASEAN+3 Macroeconomic Research Office) តុល្យភាពគណនេយ្យចរន្តរបស់ បណ្តាប្រទេសដែលជា




*ប្រភព៖ AMRO-AREO*

សមាជិកអាស៊ានទាំងដប់ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ ២០២២បានបង្ហាញថា មានតែប្រទេសសិង្ហបុរី ព្រុយណេ វៀតណាម ម៉ាឡេស៊ី និងថៃ ប៉ុណ្ណោះ ដែលគណនេយ្យចរន្តមានអតិរេក។ ក្នុងនោះអតិរេកគណនេយ្យចរន្តរបស់ប្រទេសសិង្ហបុរី មានទំហំធំជាងគេគិតជាភាគរយនៃ ផ.ស.ស។ នៅក្នុងឆ្នាំ២០១៩ អតិរេកគណនេយ្យចរន្តរបស់សិង្ហបុរីមានទំហំប្រមាណជា ១៤,៣% នៃផ.ស.ស និងអាចកើនដល់ ១៩,៣% នៃផ.ស.ស ក្នុងឆ្នាំ២០២២។ បន្ទាប់មកអតិរេកគណនេយ្យចរន្តនៅប្រទេសព្រុយណេមានទំហំជាមធ្យមប្រមាណជា ៥,១% នៃផ.ស.ស ចាប់ពីឆ្នាំ ២០១៩ ដល់ឆ្នាំ២០២២។ ចំណែកអតិរេកគណនេយ្យចរន្តនៅប្រទេសវៀតណាមចាប់ពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២២ មានទំហំជាមធ្យមប្រមាណជា ៤,៦% នៃផ.ស.ស ម៉ាឡេស៊ី ៣,៤% នៃផ.ស.ស និងថៃមានទំហំជាមធ្យម ៣,៣% នៃផ.ស.ស (សូមមើលរូបភាពខាងលើ)។

ដោយឡែក តុល្យភាពគណនេយ្យចរន្តនៅប្រទេសហ្វីលីពីនវិញ ហាក់ដូចជាឡើងចុះមិនស្ថិតស្ថេរឡើយ នេះបើយោងតាមទិន្នន័យដែលបានបង្ហាញនៅក្នុងរូបភាពខាងលើ។ ឧទាហរណ៍៖ នៅក្នុងឆ្នាំ២០១៩ និងឆ្នាំ២០២២ តុល្យភាពគណនេយ្យចរន្តរបស់ហ្វីលីពីនមានឱនភាពគួរឱ្យកត់សំគាល់ ប៉ុន្តែនៅក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ មានអតិរេក។ ស្រដៀងគ្នានេះដែរ តុល្យភាពគណនេយ្យចរន្តរបស់ឡាវ នៅក្នុងឆ្នាំ២០២០ មានអតិរេក ប៉ុន្តែនៅក្នុងឆ្នាំផ្សេងៗទៀតបែជាមានឱនភាព ក្នុងទំហំពី(-៤,០%) នៃផ.ស.ស ទៅ (-៥,០%)នៃផ.ស.ស ខណៈដែលតុល្យភាពគណនេយ្យចរន្តនៅប្រទេសមីយ៉ាន់ម៉ា មានឱនភាពជាមធ្យម(-២,៣%)នៃផ.ស.ស និងឥណ្ឌូនេស៊ី(-១,៨%) នៃផ.ស.ស។

គួរបញ្ជាក់ផងដែរថា ឱនភាពនៃតុល្យភាពគណនេយ្យចរន្តរបស់កម្ពុជា មានទំហំធំជាងគេ។ នៅឆ្នាំ២០១៩ គណនេយ្យចរន្តរបស់កម្ពុជាមានឱនភាពដល់ទៅ (-១៥,០%)នៃផ.ស.ស ឆ្នាំ២០២០មានឱនភាព (-១០,៣%) នៃផ.ស.ស និងឆ្នាំ២០២១ មានឱនភាព (-១៧,៥%)នៃផ.ស.ស។ ប៉ុន្តែយោងតាមការព្យាករណ៍របស់ AMRO តុល្យភាពគណនេយ្យចរន្តរបស់កម្ពុជានៅក្នុងឆ្នាំ២០២២ បែរជាមានអតិរេកដល់ទៅ ១៦,១%នៃផ.ស.ស ដែលជាតួរលេខខ្ពស់ជាងគេ បើធៀបទៅនឹងបណ្ដាប្រទេសផ្សេងទៀតក្រៅពីសិង្ហបុរី៕ *ដោយ វង្ស ច័ន្ទរស្មីដារា*

*ប្រភព៖ AMRO ចេញផ្សាយឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### គម្រោងអត្ថប្រយោជន៍សម្រាប់អ្នកគ្មានការងារធ្វើរបស់សហរដ្ឋអាមេរិក បានដល់កាលកំណត់




*ប្រភព៖ The New York Times ២០២១, រូបភាព៖ Gabriela Bhaskar*

ការពន្យារបន្ថែមនៃគម្រោងអត្ថប្រយោជន៍សម្រាប់អ្នកគ្មានការងារធ្វើ ក្នុងសហរដ្ឋអាមេរិក បានឈានដល់កាលកំណត់ថ្មីៗនេះ។ គម្រោងនេះ បានជួយគាំទ្រដល់ប្រជាពលរដ្ឋអាមេរិករាប់លាននាក់ ដែលមិនមានការងារធ្វើក្នុងកំឡុងវិបត្តិជំងឺកូវីដ-១៩ ដើម្បីមានលទ្ធភាពក្នុងការផ្គត់ផ្គង់ជីវភាព។ គួរបញ្ជាក់ថា លោកប្រធានាធិបតី Biden និងក្រុមទីប្រឹក្សាសេដ្ឋកិច្ចរបស់លោក មិនមានការជំទាស់ទៅលើការបញ្ចប់នៃគម្រោងនេះឡើយ (គម្រោងនេះ បានផ្ដល់ជំនួយគាំទ្រទៅដល់ប្រជាជនប្រមាណ ៧,៥លាននាក់)។

កាលពីខែមីនាកន្លងទៅ ប្រធានាធិបតី Biden បានចុះហត្ថលេខាទៅលើកញ្ចប់ជំនួយសេដ្ឋកិច្ច ដែលមានតម្លៃ ១,៩ទ្រីលានដុល្លារ ដែលក្នុងនោះ រួមមានទាំងការពន្យារបន្ថែម និងការពង្រីកអត្ថប្រយោជន៍សម្រាប់កម្មករគ្មានការងារ។ ដែលជាលទ្ធផល នៅពេលកញ្ចប់ជំនួយនេះ ឈានដល់កាលបរិច្ឆេទកំណត់ នាំឱ្យប្រជាជនអាមេរិក ៧,៥លាននាក់បាត់បង់អត្ថប្រយោជន៍ទាំងស្រុង និងបន្ថែមពីនេះ ប្រជាជន ៣លាននាក់

បន្ថែមទៀត បាត់បង់ជំនួយបន្ថែម ៣០០ដុល្លារ ប្រចាំសប្តាហ៍។

គួរឱ្យកត់សម្គាល់ផងដែរ គណបក្សសាធារណរដ្ឋ (Republicans) លើកឡើងថា ការពន្យារបន្ថែមនៃគម្រោងនេះ នឹងទាញបង្អាក់ទៅលើការងើបឡើងវិញនៃសេដ្ឋកិច្ច និងបង្កឱ្យមានការខ្វះខាតកម្លាំងពលកម្ម ខណៈដែល គណបក្សប្រជាធិបតេយ្យសេរីនិយម(Liberal Democrats) និងក្រុមវឌ្ឍជន(Progressive groups) អះអាងថា ប្រជាជនអាមេរិករាប់លាននាក់ នៅមានភាពទន់ខ្សោយ និងត្រូវការជំនួយគាំទ្រ។ ជាក់ស្តែង ជុំវិញបញ្ហានេះដែរ ប្រធានាធិបតី Biden និងទីប្រឹក្សារបស់លោក បានបដិសេធក្នុងការស្នើសុំពន្យារបន្ថែមទៅលើគម្រោងនេះ។ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ [The New York Times] ចេញផ្សាយ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១*

## សហព័ន្ធអារ៉ាប់រួម ប្រកាសពីគម្រោង និងការផ្តួចផ្តើមថ្មីចំនួន៥០ ដើម្បីជំរុញសេដ្ឋកិច្ច



*ប្រភព៖ CNBC ២០២១, រូបភាព៖ Christopher Pike | Bloomberg*

គម្រោង និងការផ្តួចផ្តើមថ្មី ចំនួន៥០ របស់សហព័ន្ធអារ៉ាប់រួម នឹងត្រូវប្រកាសនៅប៉ុន្មានសប្តាហ៍ខាងមុខនេះ ចំពេលពិធីបុណ្យខួបលើកទី៥០ បើយោងតាមមន្ត្រីសហព័ន្ធអារ៉ាប់រួម។ បន្ថែមពីនេះ អារ៉ាប់រួម បានចាប់ផ្តើមអនុវត្តកម្មវិធីមួយចំនួន ដើម្បីជំរុញ និងធ្វើពិពិធកម្មសេដ្ឋកិច្ច ក្នុងការទាក់ទាញវិនិយោគបរទេសថ្មី ១៥០ប៊ីលានដុល្លារ សម្រាប់ទសវត្សខាងមុខ។

ទន្ទឹមនេះដែរ រដ្ឋមន្ត្រីរដ្ឋសម្រាប់វិទ្យាសាស្ត្រជឿនលឿនទី១ (Minister of State for Advanced Sicence) បានប្រាប់ទៅកាន់ CNBC ថា ផែនការរបស់សហព័ន្ធអារ៉ាប់រួម សម្រាប់៥០ឆ្នាំខាងមុខ គឺក្លាយជា តួអង្គសកលមួយ នៅក្នុងឧស្សាហកម្មគ្រប់ប្រភេទ។ អារ៉ាប់រួម មានគោលដៅក្នុងការវិនិយោគយ៉ាងខ្លាំងទៅលើឧស្សាហកម្មជឿនលឿន និងការអប់រំតាមប្រព័ន្ធបច្ចេកវិទ្យា។

គួរបញ្ជាក់ថា នៅក្នុងគម្រោង និងការផ្តួចផ្តើមថ្មី ក៏រួមមានទាំង គម្រោងទិដ្ឋាការថ្មី ដែលមានគោលបំណងទាក់ទាញនិវាសនជន និងកម្មករមានជំនាញ តាមរយៈការដាក់អនុវត្តនូវទិដ្ឋាការបៃតង(Green Visa) សម្រាប់បុគ្គល និងអ្នកវិនិយោគមានជំនាញ និងទិដ្ឋាការសម្រាប់អ្នកធ្វើការក្រៅក្របខណ្ឌ(Freelancers Visa)។ ទិដ្ឋាការគឺជាសសរស្តម្ភស្នូលនៃសេដ្ឋកិច្ចអារ៉ាប់រួម ដោយប្រជាជនជិត ៩០% នៃប្រជាជនសរុប(១០លាននាក់) គឺជាជនចំណាកស្រុក៕

*ដោយ **ជា សិរីរតន៍***

*ប្រភព៖ [CNBC] ចេញផ្សាយ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១*

## ផែនការកំណត់ពន្ធ លើការបញ្ចេញកាបូនរបស់សហភាពអឺរ៉ុប នឹងប៉ះពាល់ដល់សេដ្ឋកិច្ចប្រទេសជាច្រើន



*ប្រភព៖ sbm news, 2021*

សហភាពអឺរ៉ុប បានស្នើកាលពីខែកក្កដា នូវយន្តការកែសម្រួលព្រំដែនកាបូន (CBAM) ឬពន្ធលើកាបូនឌីអុកស៊ីតលើទំនិញនាំឱ្យមានការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ចាប់ពីឆ្នាំ២០២៦ ដោយបង្ខំឱ្យក្រុមហ៊ុនមួយចំនួនដែលនាំចូលទំនិញទៅក្នុងសហភាពអឺរ៉ុប បង់ថ្លៃចំពោះការបញ្ចេញកាបូនលើផលិតផលដែលមានជាតិកាបូន ដូចជា ដែកថែប អាលុយមីញ៉ូម និងដី។ នៅក្រោមប្រព័ន្ធពាណិជ្ជកម្មការបំភាយឧស្ម័ន របស់សហភាពអឺរ៉ុប ក្រុមហ៊ុនមានកាតព្វកិច្ចបង់ប្រាក់ឧបត្ថម្ភ ដើម្បីគ្របដណ្តប់ការបញ្ចេញកាបូនឌីអុកស៊ីតទាំងអស់របស់ពួកគេ។ CBAM នឹងត្រូវបានណែនាំនៅឆ្នាំ២០២៣ មុនពេលចាប់ផ្តើមដំណើរការពេញលេញនៅឆ្នាំ ២០២៦ យោងតាមសំណើរបស់គណៈកម្មការអឺរ៉ុប។

ចំពោះ វិស័យដែលគ្របដណ្តប់ដោយគ្រោងការណ៍នេះ មានត្រឹមតែប្រមាណ ៣,២%នៃការនាំចូលសរុបចូលមកក្នុងសហភាពអឺរ៉ុបជារៀងរាល់ឆ្នាំ ប៉ុន្តែការបញ្ចេញឧស្ម័នកាបូនិករបស់ពួកគេ គឺស្មើនឹងប្រមាណ ៤៧% នៃប្រាក់សម្រាប់ការសាយភាយកាបូនឌីអុកស៊ីត។

ផែនការកំណត់ពន្ធលើកាបូននៅតាមព្រំដែនដំបូងបង្អស់របស់ពិភពលោកដែលស្នើដោយសហភាពអឺរ៉ុប គឺរុស្ស៊ីនឹងបង់នៅឆ្នាំ២០២៦ រីឯអ៊ុយក្រែន ទួរគី និងចិន ត្រូវបានគេរំពឹងថានឹងបង់ប្រាក់ នៅឆ្នាំ២០៣៥។

ផែនការកំណត់ពន្ធកាបូនរបស់សហភាពអឺរ៉ុបមួយនេះ បានកើតឡើងចំពេលមានភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ និងពាណិជ្ជកម្មអន្តរជាតិកើនឡើង។ ប្រទេសចិន បានរិះគន់ជាសាធារណៈចំពោះសំណើនេះ ដោយនិយាយថា វានឹងប៉ះពាល់ដល់ចក្ខុវិស័យកំណើនសេដ្ឋកិច្ច៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ sbm.news ចេញផ្សាយថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២១។*

## សេដ្ឋកិច្ចឥណ្ឌាបានស្ទុះឡើង២០% ក្នុងត្រីមាសទី២ឆ្នាំនេះ ក្រោយអត្រាចាក់វ៉ាក់សាំងកើនឡើងជាលំដាប់



*ដោយ វុធ ច័ន្ទតារា*

សេដ្ឋកិច្ចឥណ្ឌាកាលពីត្រីមាសទី២ឆ្នាំ២០២១នេះ បានហក់ឡើងក្នុងអត្រា២០% ទោះបីជា បានរងគ្រោះយ៉ាងដំណំពីរលកឆ្លងកូវីដ១៩ ដ៏កាចសាហាវ ប៉ះពាល់ទាំងសេដ្ឋកិច្ច និងសុខភាពសាធារណៈក្តី។

កំណើននេះបានមកពីការជួយរុញច្រានដោយយុទ្ធនាការចាក់វ៉ាក់សាំងបានចំនួនច្រើនទៅៗ ដែលធ្វើឱ្យគេអាចឈានទៅគ្រប់គ្រងលើការឆ្លងរាលដាលកូវីដ១៩ ហើយ

អាចអនុញ្ញាតឱ្យសកម្មភាពសេដ្ឋកិច្ចក្នុងវិស័យនានាដំណើរការជាធម្មតាឡើងវិញ។ ជាក់ស្តែង វិស័យសំណង់របស់ឥណ្ឌាបានងើបឡើងវិញក្នុងអត្រា៦៨%, វិស័យផលិតកម្មឧស្សាហកម្ម បានពង្រីកខ្លួនដល់ជិត ៥០% និងវិស័យកសិកម្មវិញបានកើនឡើង៤,៥%។

*តើអ្វី ជាមូលហេតុនៅពីក្រោយកំណើនសេដ្ឋកិច្ចនេះ ទោះរងគ្រោះខ្លាំងដោយសាររលកឆ្លងកូវីដ១៩?*

គេនៅចាំបានថា កាលពីរលកឆ្លងលើកដំបូងនៅឥណ្ឌាកាលពីឆ្នាំ២០២០ ការរាលដាលមិនមានច្រើនខ្លាំងមែន ប៉ុន្តែរដ្ឋាភិបាលក្រុងញ៉ូដេលី បានដាក់ចេញវិធានការណ៍តឹងរឹងបំផុត ដោយបិទខ្ទប់ទាំងស្រុងនៅទូទាំងប្រទេសតែម្តង ទោះបីជាតំបន់ខ្លះមិនមានករណីវិជ្ជមានក៏ដោយ។ ប្រការនេះបានធ្វើឱ្យប៉ះពាល់ខ្លាំងដល់សកម្មភាពសេដ្ឋកិច្ច អាជីវកម្មទាំងតូចទាំងធំនៅឥណ្ឌា។

ក្រោយមក នៅគ្រាដែលឥណ្ឌាជួបប្រទះនឹងរលកឆ្លងលើកទី២ក្នុងឆ្នាំ២០២១ ទោះការឆ្លងមានសភាពខ្លាំងជាងមុនក៏ពិតមែន តែរដ្ឋាភិបាលបានបញ្ជាឱ្យបិទខ្ទប់តែតំបន់ណាដែលមានករណីឆ្លងខ្លាំងប៉ុណ្ណោះ ខណៈតំបន់ផ្សេងៗត្រូវដាក់ចេញនូវបម្រាមគោចរណ៍។ ប្រការនេះហើយ ដែលអនុញ្ញាតឱ្យសកម្មភាពសេដ្ឋកិច្ចឥណ្ឌានៅបន្តដង្ហើមបាន ជាហេតុធ្វើឱ្យប្រទេសសេដ្ឋកិច្ចធំលំដាប់ទី៣នៅអាស៊ីមួយនេះ មើលឃើញពីកំណើនសេដ្ឋកិច្ចខ្លាំងដូចពេលនេះ។

សេដ្ឋកិច្ចឥណ្ឌាត្រូវបានស្ថាប័នរដ្ឋ និងអន្តរជាតិនានាព្យាករណ៍ថា នឹងមានកំណើនក្នុងរង្វង់ ៩%នៅពេញមួយឆ្នាំ២០២១នេះ ប៉ុន្តែអ្នកសេដ្ឋកិច្ចបានអះអាងថា ប្រសិនបើការចាក់វ៉ាក់សាំងដំណើរការទៅបានរលូន និងក្នុងចំនួនកាន់តែច្រើន នោះសេដ្ឋកិច្ចឥណ្ឌាអាចនឹងមានកំណើនលើសពីការព្យាករណ៍នេះទៅទៀត៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ cambonomist ចេញផ្សាយនាថ្ងៃទីសុក្រ ទី០៣ ខែកញ្ញា ឆ្នាំ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី១៣ ខែកញ្ញា ឆ្នាំ២០២១

- ការប៉ាន់ស្មានបឋម បានបង្ហាញថាសេដ្ឋកិច្ចអារ៉ាប៊ីសាអូឌីតបានកើនឡើង ១,៥%នៅត្រីមាសទី ២ នៃឆ្នាំ ២០២១
- អត្រាអតិផរណាតម្លៃលក់រាយរបស់ឥណ្ឌាបានធ្លាក់ចុះដល់៥,៥៩%នៅខែកក្កដាឆ្នាំ ២០២១

ថ្ងៃអង្គារ ទី១៤ ខែកញ្ញា ឆ្នាំ២០២១

- សហរដ្ឋអាមេរិក បានបង្ហាញពីឱនភាពថវិកានៅក្នុងខែកក្កដាឆ្នាំ ២០២១
- កំណើនចំនួនមនុស្សធ្វើការនៅអង់គ្លេស គិតត្រឹមខែមិថុនាឆ្នាំ ២០២១

ថ្ងៃពុធ ទី១៥ ខែកញ្ញា ឆ្នាំ២០២១

- អត្រាអតិផរណានៅក្នុងប្រទេសអាហ្សង់ទីនបានកើនឡើងដល់ ៥១,៨០% នៅខែកក្កដា ពី ៥០,២០%នៅខែមិថុនាឆ្នាំ ២០២១
- អត្រាគ្មានការងារធ្វើនៅប្រទេសកូរ៉េខាងត្បូងបានធ្លាក់ចុះមកនៅត្រឹម ៣,៣% នៅខែកក្កដាឆ្នាំ ២០២១ ពី ៣,៧% នៅក្នុងខែមុន

ថ្ងៃព្រហស្បតិ៍ ទី១៦ ខែកញ្ញា ឆ្នាំ២០២១

- ប្រទេសជប៉ុនបានប្រកាសអតិរេកពាណិជ្ជកម្មចំនួន ៤៤១,០២ ពាន់លានយ៉េននៅខែកក្កដាឆ្នាំ ២០២១

- ការងារពេញម៉ោងនៅអូស្ត្រាលី បានធ្លាក់ចុះចំនួន ៤ ២០០ ក្នុងខែកក្កដាឆ្នាំ ២០២១

ថ្ងៃសុក្រ ទី១៧ ខែកញ្ញា ឆ្នាំ២០២១

- កំណើនទុនបំរុងរូបិយប័ណ្ណបរទេសនៅក្នុងប្រទេសឥណ្ឌាបាន កើនដល់ ៦៣៣ ៥៥៨ លានដុល្លារនៅថ្ងៃទី២៧ខែសីហា ពីចំនួន ៦១៦ ៩០០ លានដុល្លារនៅក្នុងសប្តាហ៍មុន
- កំណើនបរិមាណលក់រាយនៅអង់គ្លេស បានកើនឡើង ២,៤% នៅខែកក្កដាឆ្នាំ ២០២១៕